# សំណួរដែលបានសួរញឹកញាប់ (FAQ)

តុលាការបណ្ដឹងតូចតាចមិនមែនជាតុលាការដាច់ដោយឡែកឡើយ ប៉ុន្តែជាសម័យប្រជុំពិសេសរបស់តុលាការស្រុក, តុលាការក្រុងបូស្តុន ឬក៏តុលាការទីលំនៅ។ តុលាការនេះត្រូវបានបង្កើតឡើងដើម្បីផ្ដល់នីតិវិធីមួយទៀតដែលសាមញ្ញ ក្រៅផ្លូវការ និងមិនថ្លៃ ក្នុងការដោះស្រាយរឿងក្ដីតូចតាច ($7,000 ឬ តិចជាងនេះ)។ ព័ត៌មានខាងក្រោមត្រូវបានផ្ដល់ជូនដើម្បីជួយអ្នកដែលចង់ធ្វើបណ្ដឹងតូចតាច នៅតុលាការណាមួយដែលបានរាយខាងលើ។

## I. ឧបញ្ញត្តិ, វិធាន និង បទដ្ឋាននៃបណ្ដឹងតូចតាច

នីតិវិធីក្នុងការប្ដឹងផ្ដល់ចំពោះបណ្ដឹងតូចតាចមាននៅក្នុងច្បាប់ទូទៅរបស់រដ្ឋម៉ាសាជូសេត និង អាចរកបាននៅ G.L. c. 218, §§ 21-25 [add hyperlink]។ វិធាននៃបណ្ដឹងតូចតាចឯករូបមាននៅទីនេះ [add hyperlink]។ បទដ្ឋាននៃបណ្ដឹងតូចតាចបង្ហាញពីការអនុវត្តដែលបានផ្ដល់យោបល់ឲ្យសម្រាប់នីតិវិធីនៃបណ្ដឹងតូចតាច។ បទដ្ឋានទាំងនេះគឺជាការផ្ដល់យោបល់ឲ្យដើម្បីអនុវត្តឧបញ្ញត្តិនៃបណ្ដឹងតូចតាច។

## II. សំណួរដែលបានសួរញឹកញាប់៖

- តើខ្ញុំអាចធ្វើបណ្ដឹងតូចតាចដូចម្ដេច?
- តើកន្លែងណាដែលខ្ញុំអាចដាក់បណ្ដឹងតូចតាចបាន?
- តើបណ្ដឹងណាដែលអាចប្ដឹងជាបណ្ដឹងតូចតាច?
- តើខ្ញុំអាចធ្វើបណ្ដឹងតូចតាចដោយផ្អែកលើការធ្វេសប្រហែសរបស់និយោជិតសាធារណៈដែរឬទេ?
- តើមានដែនកំណត់ពេលវេលាដែរឬទេ ចំពោះពេលណាដែលខ្ញុំត្រូវធ្វើបណ្ដឹងតូចតាច?
- តើខ្ញុំនឹងអាចប្រមូលប្រាក់ពីចុងចោទមែនទេ?
- តើថ្លៃដាក់បណ្ដឹងតូចតាចមានចំនួនប៉ុន្មាន?
- តើព័ត៌មានអ្វីដែលខ្ញុំត្រូវរួមបញ្ចូលក្នុងបណ្ដឹងតូចតាចរបស់ខ្ញុំ?
- តើមាន “សោហ៊ុយ” អ្វីខ្លះ?
- តើមានតម្រូវការពិសេសដែរឬទេ ប្រសិនបើបណ្ដឹងនេះបានកើតឡើងពីអាជីវកម្មរបស់ខ្ញុំ?
- តើចុងចោទទទួលដំណឹងពីបណ្ដឹងនេះដូចម្ដេច?
- តើរឿងក្ដីរបស់ខ្ញុំនឹងបន្តទៅមុខទៀតដែរឬទេ ប្រសិនបើចុងចោទមិនបានទទួលសេចក្ដីជូនដំណឹង?
- តើត្រូវការមេធាវីដែរឬទេ នៅក្នុងតុលាការបណ្ដឹងតូចតាច?
- តើចុងចោទត្រូវបានតម្រូវឲ្យដាក់ឯកសារចម្លើយដែរឬទេ?
- ចុះប្រសិនបើចុងចោទព្រមទទួលថាជំពាក់ប្រាក់ទាំងអស់?
- ចុះប្រសិនបើចុងចោទព្រមទទួលថាជំពាក់ប្រាក់ ប៉ុន្តែត្រូវការពេលដើម្បីសង?
- ចុះប្រសិនបើចុងចោទយល់ថាគាត់មិនជំពាក់អ្វីទាំងអស់ ឬ ជំពាក់តែប្រាក់ខ្លះដែលបានប្ដឹងនោះ?
- ចុះប្រសិនបើចុងចោទយល់ថាដើមចោទជាអ្នកជំពាក់ប្រាក់គាត់វិញ?
- តើពេលណា ឬ កន្លែងណាដែលដើមចោទ និង ចុងចោទត្រូវទៅតុលាការ?
- តើមានការសម្រុះសម្រួលដែរឬទេចំពោះបណ្ដឹងតូចតាច?
- ចុះប្រសិនបើខ្ញុំមិនអាចមកតុលាការនៅថ្ងៃកាត់ក្ដី?
- ចុះប្រសិនបើខ្ញុំមិនមកតុលាការនៅថ្ងៃកាត់ក្ដី?
- តើខ្ញុំត្រូវត្រៀមខ្លួនសម្រាប់ការកាត់ក្ដីដូចម្ដេច?
- តើនឹងមានអ្វីកើតឡើងនៅថ្ងៃកាត់ក្ដី?
- ចុះប្រសិនបើភាគីណាមួយចង់លើកពេល?
- តើតុលាការីនឹងធ្វើអ្វីខ្លះ?
- ខ្ញុំបានចាញ់ក្ដីរបស់ខ្ញុំនៅចំពោះមុខតុលាការី។ តើខ្ញុំត្រូវធ្វើអ្វី?
- ខ្ញុំបានឈ្នះក្ដីរបស់ខ្ញុំនៅចំពោះមុខតុលាការី។ តើខ្ញុំត្រូវធ្វើអ្វី?
- តើខ្ញុំត្រូវបង្ហាញខ្លួននៅក្នុងសវនាការត្រួតពិនិត្យការសងប្រាក់ដែរឬទេ?
- តើមានការលើកលែងចំណូលណាមួយពីការបញ្ជាឲ្យសងប្រាក់ដែរឬទេ?
- ប្រសិនបើខ្ញុំឈ្នះក្ដីរបស់ខ្ញុំ តើខ្ញុំត្រូវជូនដំណឹងដល់តុលាការដែរឬទេ នៅពេលដែលខ្ញុំបានទទួលសំណង?

## III. ទម្រង់បែបបទ

ប្រសិនបើអ្នកជ្រើសរើសដាក់បណ្ដឹងតូចតាច ឬ ប្រសិនបើអ្នកគឺជាចុងចោទក្នុងករណីបណ្ដឹងតូចតាច តុលាការកាត់ក្ដីមានទម្រង់បែបបទដែលនឹងមានប្រយោជន៍ក្នុងការនាំមកនូវបញ្ហាសមស្របជូនឲ្យតុលាការចាប់អារម្មណ៍។ ទម្រង់បែបបទបណ្ដឹងតូចតាចទាំងអស់អាចរកបាននៅការិយាល័យស្មៀននៃតុលាការស្រុកណាមួយ, តុលាការក្រុងបូស្តុន ឬ តុលាការទីលំនៅ។ ដើម្បីទទួលបញ្ជីនៃទីកន្លែងតុលាការទាំងនេះតាមខោនធី សូមចុចទីនេះ [add hyperlink]។ បន្ថែមលើនេះ ទម្រង់បែបបទទាំងអស់ដែលបានប្រើនៅក្នុងករណីបណ្ដឹងតូចតាចអាចទាញយកបានខាងក្រោម លើកលែងតែ “សេចក្ដីថ្លែងការណ៍អំពីបណ្ដឹង និង សេចក្ដីជូនដំណឹងអំពីការកាត់ក្ដី” ប៉ុណ្ណោះ។ សេចក្ដីណែនាំអំពីការបំពេញទម្រង់បែបបទ “សេចក្ដីថ្លែងការណ៍អំពីបណ្ដឹងតូចតាច និង សេចក្ដីជូនដំណឹងអំពីការកាត់ក្ដី” អាចរកបាននៅទីនេះ [add hyperlink]។

សេចក្ដីថ្លែងការណ៍អំពីបណ្ដឹង និង សេចក្ដីជូនដំណឹងអំពីការកាត់ក្ដី

ការផ្ទៀងផ្ទាត់អាសយដ្ឋានរបស់ចុងចោទ



This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.

ចម្លើយនៃបណ្តឹងតូចតាច

បណ្តឹងតបនឹងបណ្តឹងតូចតាច

ញត្តិគោលបំណងទូទៅ

ការផ្ទៀងផ្ទាត់អាសយដ្ឋានរបស់ចុងចោទ

របាយការណ៍ហិរញ្ញវត្ថុរបស់កូនបំណុលនៃការវិនិច្ឆ័យ

ការបង្ហាញខ្លួនរបស់ស្មាក្តី (ភាសាអង់គ្លេសប៉ុណ្ណោះ)

ការបង្ហាញខ្លួនរបស់ស្មាក្តីជំនួស (ភាសាអង់គ្លេសប៉ុណ្ណោះ)

កិច្ចព្រមព្រៀងសម្រាប់ការវិនិច្ឆ័យ និង សម្រាប់ការបញ្ជាឲ្យសងប្រាក់

បញ្ជីនៃការលើកលែង

កិច្ចព្រមព្រៀងសម្រាប់ការបញ្ជាឲ្យសងប្រាក់ (ជាមួយការលើកលែង)

របាយការណ៍ហិរញ្ញវត្ថុរបស់កូនបំណុលនៃការវិនិច្ឆ័យ

បណ្តឹងសាទុក្ខរបស់ចុងចោទ

ការទទួលស្គាល់អំពីការជម្រះបំណុលនៃការវិនិច្ឆ័យ

ការទទួលស្គាល់អំពីការជម្រះបំណុលនៃការវិនិច្ឆ័យលើបណ្តឹងតប

## IV. ចម្លើយចំពោះសំណួរដែលបានសួរញឹកញាប់

### 1. តើខ្ញុំអាចធ្វើបណ្តឹងតូចតាចដូចម្តេច?

ដោយការដាក់ទម្រង់បែបបទរបស់តុលាការ មានចំណងជើងថា "សេចក្តីថ្លែងការណ៍អំពីបណ្តឹង និង សេចក្តីជូនដំណឹងអំពីការកាត់ក្តី" និង ការបង់ថ្លៃដាក់ពាក្យ។ ទម្រង់បែបបទនេះអាចរកបាននៅការិយាល័យស្មៀននៃតុលាការស្រុកណាមួយ, តុលាការក្រុងបូស្តុន ឬ តុលាការទីលំនៅ។ សេចក្តីណែនាំអំពីការបំពេញទម្រង់បែបបទ "សេចក្តីថ្លែងការណ៍អំពីបណ្តឹងតូចតាច និង សេចក្តីជូនដំណឹងអំពីការកាត់ក្តី" អាចរកបាននៅទីនេះ http://www.mass.gov/courts/courtsandjudges/courts/courtscounty.html. ។ បុគ្គល ឬ អាជីវកម្មដែលដាក់បណ្តឹង ត្រូវបានគេហៅថា "ដើមចោទ"។ បុគ្គល ឬ អាជីវកម្មដែលត្រូវបានគេប្តឹង ត្រូវបានគេហៅថា "ចុងចោទ"។

### 2. តើកន្លែងណាដែលខ្ញុំអាចដាក់បណ្តឹងតូចតាចបាន?

អ្នកអាចដាក់បណ្តឹងតូចតាចបានតែនៅតុលាការក្នុងតំបន់ដែលដើមចោទ ឬ ចុងចោទរស់នៅ ឬក៏មានកន្លែងអាជីវកម្ម ឬ ការងារប៉ុណ្ណោះ។ បណ្តឹងតូចតាចប្រឆាំងនឹងម្ចាស់ផ្ទះ ដែលកើតឡើងពីការជួលផ្ទះ ក៏អាចនាំទៅកន្លែងដែលផ្ទះនោះស្ថិតនៅផងដែរ។ អ្នកអាចឃើញថាកាន់តែងាយស្រួលក្នុងការអនុវត្តសេចក្តីសម្រេច ដោយអនុគ្រោះចំពោះអ្នក ប្រសិនបើអ្នកដាក់បណ្តឹងតូចតាចរបស់អ្នកនៅកន្លែងដែលចុងចោទរស់នៅ ឬ ធ្វើការ ប៉ុន្តែអ្នកមិនត្រូវបានតម្រូវឲ្យធ្វើដូច្នោះឡើយ។

### 3. តើបណ្តឹងណាដែលអាចប្តឹងជាបណ្តឹងតូចតាច?

លុះត្រាតែរឿងក្តីរបស់អ្នកផ្អែកលើការខូចខាតទ្រព្យសម្បត្តិនៅក្នុងគ្រោះថ្នាក់ចរាចរណ៍ បើមិនដូច្នោះទេ វាមិនអាចលើសពី $7,000.00 ឡើយ។ ទោះជាយ៉ាងនេះក្តី បណ្តឹងនោះអាចស្ថិតនៅក្រោមការខូចខាតតាមច្បាប់ ឬ ថ្លៃរបស់មេធាវី លើសពី $7,000.00 (ឧទា. រឿងក្តីការពារអ្នកប្រើប្រាស់ ឬ រឿងក្តីម្ចាស់ផ្ទះ/អ្នកជួល មួយចំនួន)។ ក្នុងរឿងក្តីទាំងនោះ ចំនួនមូលដ្ឋានមិនអាចលើសពី $7,000.00 ឡើយ សូម្បីតែសំណងអាចលើសពីចំនួននោះក៏ដោយ។

### 4. តើខ្ញុំអាចធ្វើបណ្តឹងតូចតាចដោយផ្អែកលើការឆ្វេសប្រហែសរបស់និយោជិតសាធារណៈដែរឬទេ?

ជាទូទៅមិនអាចឡើយ។ បណ្តឹងភាគច្រើនចំពោះការខូចខាតប្រាក់ ប្រឆាំងនឹងខំមុនវែល, ទីភ្នាក់ងារ ឬ អាជ្ញាធររដ្ឋ ឬក៏ទីក្រុង ឬ ក្រុង ដែលផ្អែកលើការធ្វេសប្រហែស ឬ ការប្រព្រឹត្តិកំហុសរបស់មន្ត្រី ឬ និយោជិតសាធារណៈ ត្រូវតែដាក់ក្រោម ច្បាប់បណ្តឹងចំពោះកំហុសរដ្ឋប្បវេណីនៅរដ្ឋម៉ាសាជូសេត, ច្បាប់ទូទៅនៅរដ្ឋម៉ាសាជូសេត ជំពូក 258 [add hyperlink]។ បណ្តឹងក្រោម ច្បាប់បណ្តឹងចំពោះកំហុសរដ្ឋប្បវេណីនៅរដ្ឋម៉ាសាជូសេត ត្រូវតែដាក់នៅតុលាការជាន់ខ្ពស់ និង មិនអាចដាក់ជាបណ្តឹងតូចតាចឡើយ។ អ្នកអាចដាក់ជាបណ្តឹងតូចតាច នូវបណ្តឹងដែលផ្អែកលើកិច្ចសន្យារបស់រដ្ឋាភិបាល, បណ្តឹងប្រឆាំងនឹងអាជ្ញាធរទីលំនៅ ឬ បណ្តឹងដែលទទួលការអនុញ្ញាតដោយច្បាប់ដទៃខ្លះទៀតដូចជា "ច្បាប់គ្រលុក" នៃច្បាប់ទូទៅនៅរដ្ឋម៉ាសាជូសេត ជំពូក 84 មាត្រា 15 សម្រាប់ផ្លូវក្រុង ឬ ជំពូក 81 មាត្រា 18 សម្រាប់ផ្លូវរដ្ឋ [add hyperlinks]។

### 5. តើមានដែនកំណត់ពេលវេលាដែរឬទេ ចំពោះពេលណាដែលខ្ញុំត្រូវធ្វើបណ្តឹងតូចតាច?

មាន។ ដែនកំណត់ពេលវេលា (ហៅថា "អាជ្ញាយុកាល") ខុសគ្នាទៅតាមលក្ខណៈនៃបណ្តឹង និង អនុវត្តទាំងលើបណ្តឹងតូចតាច និង បណ្តឹងរដ្ឋប្បវេណីធម្មតា។ ជាទូទៅ បណ្តឹងដែលផ្អែកលើកិច្ចសន្យា ឬ ច្បាប់ការពារអ្នកប្រើប្រាស់ត្រូវតែធ្វើក្នុងរយៈពេល 6 ឆ្នាំ ហើយបណ្តឹងដែលកើតឡើងពីការធ្វេសប្រហែស ឬ ការបង្កអន្តរាយដោយចេតនា ត្រូវតែធ្វើក្នុងរយៈពេល 3 ឆ្នាំ ប៉ុន្តែក៏មានការលើកលែងផងដែរ។ មើលច្បាប់ទូទៅនៅរដ្ឋម៉ាសាជូសេត ជំពូក 260 ឬ នៅបណ្ណាល័យសាធារណៈ ឬ បណ្ណាល័យច្បាប់ ដើម្បីទទួលព័ត៌មានបន្ថែម។



This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.

## 6. តើខ្ញុំនឹងអាចប្រមូលប្រាក់ពីចុងចោទមែនទេ?

ប្រសិនបើអ្នកឈ្នះក្តី ចុងចោទនឹងត្រូវបានបញ្ជាឲ្យសងប្រាក់នៃការវិនិច្ឆ័យ ប្រសិនបើគេមានលទ្ធភាពខាងហិរញ្ញវត្ថុក្នុងការធ្វើដូច្នោះ។ ប្រសិនបើចុងចោទមានលទ្ធភាពសងប្រាក់ តែគេមិនសង គេអាចត្រូវបានចាត់ទុកថាមិនគោរពតុលាការ និង អាចជាប់ពន្ធនាគារ ឬក៏ឲ្យបង់សោហ៊ុយបន្ថែម។ កត់សម្គាល់ថាប្រភពនៃចំណូលខ្លះ និង បៀវត្សមួយភាគនឹងត្រូវបានលើកលែងពីការបញ្ជាឲ្យសងប្រាក់។

## 7. តើថ្លៃដាក់បណ្តឹងតូចតាចមានចំនួនប៉ុន្មាន?

ថ្លៃដាក់ពាក្យសម្រាប់បណ្តឹងតូចតាចដែលមានទឹកប្រាក់ $500 និង ក្រោមនេះគឺ $40។ ថ្លៃដាក់ពាក្យសម្រាប់បណ្តឹងដែលមានទឹកប្រាក់ $501 ទៅ $2000 គឺ $50។ ថ្លៃដាក់ពាក្យសម្រាប់បណ្តឹងដែលមានទឹកប្រាក់ $2001 ទៅ $5000 គឺ $100។ ថ្លៃដាក់ពាក្យសម្រាប់បណ្តឹងដែលមានទឹកប្រាក់ $5001 ទៅ $7000 គឺ $150។ ថ្លៃដាក់ពាក្យសម្រាប់បណ្តឹងដែលការខូចខាតទ្រព្យសម្បត្តិលើសពី $7000 កើតឡើងពីគ្រោះថ្នាក់ចរាចរណ៍គឺ $150។

## 8. តើព័ត៌មានអ្វីដែលខ្ញុំត្រូវរួមបញ្ចូលក្នុងបណ្តឹងតូចតាចរបស់ខ្ញុំ?

បំពេញក្នុងទម្រង់បែបបទ "សេចក្តីថ្លែងការណ៍អំពីបណ្តឹងតូចតាច" ជាមួយនឹងចំនួនដែលអ្នកកំពុងប្តឹង និង ពន្យល់បណ្តឹងរបស់អ្នកដោយសង្ខេប។ ថ្លែងអំពីបណ្តឹងរបស់អ្នកយ៉ាងសាមញ្ញ ប៉ុន្តែច្បាស់លាស់ ដូច្នេះចុងចោទអាចយល់ពីមូលហេតុដែលគេត្រូវបានប្តឹង។ អ្នកត្រូវតែថ្លែងឲ្យបានច្បាស់នូវចំនួនដែលចង់បានសម្រាប់ការខូចខាត, សម្រាប់ការខូចខាតច្រើន ឬ ការពិន័យតាមច្បាប់, សម្រាប់ថ្លៃមេធាវី ឬក៏សម្រាប់សោហ៊ុយផ្សេងៗ ព្រមទាំងចំនួនសរុបដែលចង់បាន ដោយមិនរាប់បញ្ចូល ការប្រាក់មុនការវិនិច្ឆ័យទាំងឡាយដែលចង់បានពីតុលាការ ដោយអនុលោមតាមឧបញ្ញត្តិ។

វាចាំបាច់ដែលថាអ្នកមានឈ្មោះត្រឹមត្រូវរបស់ចុងចោទ និង អាសយដ្ឋានផ្ញើសំបុត្រ។ ប្រសិនបើអ្នកកំពុងប្តឹងអាជីវកម្មមួយដែលមិនមែនជាសាជីវកម្ម អ្នកគួរសរសេរឈ្មោះចុងចោទជាម្ចាស់ដែលធ្វើអាជីវកម្មនោះ ("d/b/a") ក្រោមឈ្មោះអាជីវកម្មនោះ។ អ្នកអាចទទួលឈ្មោះរបស់ពួកគេពីស្មៀនទីក្រុង ឬ ក្រុង ដែលអាជីវកម្មនោះស្ថិតនៅ។ ប្រសិនបើអ្នកកំពុងប្តឹងអាជីវកម្មដែលជាសាជីវកម្ម អ្នកត្រូវតែមានឈ្មោះតាមផ្លូវច្បាប់ជាក់លាក់របស់គេ។ អ្នកអាចរកព័ត៌មាននេះពីផ្នែកកំណត់ត្រាសាជីវកម្ម នៃការិយាល័យរបស់លេខាធិការរដ្ឋ អាសយដ្ឋាន One Ashburton Place, Room 1712, Boston, MA 02108 (ឬ តាម http://corp.sec.state.ma.us/corp/corpsearch/corpsearchinput.asp)
ក្នុងផ្នែក "ព័ស្តុតាងយោធា" អ្នកត្រូវតែបញ្ជាក់ថាតើចុងចោទកំពុងបំពេញភារកិច្ចយោធាឬក៏អត់។ ប្រសិនបើអ្នកដឹងលេខសន្តិសុខសង្គមរបស់ចុងចោទ អ្នកអាចកំណត់ថាតើគេកំពុងបំពេញភារកិច្ចយោធាឬអត់ តាមបណ្តាញអ៊ីនធឺណិត https://www.dmdc.osd.mil/appj/scra/scraHome.do; បើមិនដូច្នោះទេ អ្នកត្រូវតែសរសេរលិខិតទៅទីស្នាក់ការសេវាយោធាដែលសមស្រប (រាយនៅ www.defenselink.mil/faq/pis/PC09SLDR.html)។ ប្រសិនបើអ្នកមិនអាចកំណត់ថាតើចុងចោទកំពុងបំពេញភារកិច្ចយោធាឬក៏អត់ទេ ហើយចុងចោទមិនអាចមកបង្ហាញខ្លួន តុលាការអាចតម្រូវឲ្យអ្នកដាក់ប្រាក់ធានា ឬក៏អាចចេញនូវការបញ្ជាផ្សេងទៀត ដើម្បីការពារសិទ្ធិរបស់ចុងចោទ ប្រសិនបើគេកំពុងបំពេញភារកិច្ចយោធា។

## 9. តើមាន "សោហ៊ុយ" អ្វីខ្លះ?

ប្រសិនបើដើមចោទឈ្នះក្តី ឬ ប្រសិនបើភាគីទាំងពីរផ្សះផ្សារគ្នាលើបណ្តឹងនេះ ដើមចោទអាចទារមកវិញពីចុងចោទនូវ "សោហ៊ុយ" ថ្លៃដាក់បណ្តឹងទៅតុលាការ។ តាមការបញ្ជារបស់តុលាការ ពេលខ្លះ ដើមចោទអាចទារមកវិញនូវសោហ៊ុយដទៃផ្សេងទៀតមួយចំនួនក្នុងការដាក់បណ្តឹងនោះ។

## 10. តើមានតម្រូវការពិសេសដែរឬទេ ប្រសិនបើបណ្តឹងនេះបានកើតឡើងពីអាជីវកម្មរបស់ខ្ញុំ?

មាន។ ប្រសិនបើបណ្តឹងរបស់អ្នកបានកើតឡើងក្នុងពេលអ្នកធ្វើជំនួញ ឬ ពាណិជ្ជកម្ម ឬក៏អ្នកកំពុងធ្វើបណ្តឹងចំពោះបំណុលដែលបានចាត់ឲ្យទារ អ្នកត្រូវតែរួមបញ្ចូលផងដែរនៅក្នុងទម្រង់បែបបទ "សេចក្តីថ្លែងការណ៍អំពីបណ្តឹងតូចតាច" នូវៈ (1) ឈ្មោះរបស់ម្ចាស់បំណុលដើម (ប្រសិនបើផ្សេងពីអ្នក), (2) តែលេខគណនីបួនខ្ទង់ចុងក្រោយណាមួយដែលបានកំណត់ដោយម្ចាស់បំណុលដើម និង (3) ចំនួន និង កាលបរិច្ឆេទនៃការសងប្រាក់ចុងក្រោយ ប្រសិនបើមាន។ ប្រសិនបើអ្នកមិនធ្វើដូច្នោះទេ ហើយចុងចោទមិនអាចមកបង្ហាញខ្លួន អ្នកប្រហែលជាមិនអាចទទួលការវិនិច្ឆ័យកំបាំងមុខ ដោយអនុគ្រោះចំពោះអ្នកឡើយ ហើយបណ្តឹងរបស់អ្នកនឹងត្រូវបានលើកចោល ទោះបីជាអ្នកអាចដាក់វាឡើងវិញក៏ដោយ។
អ្នកក៏ត្រូវដាក់ទម្រង់បែបបទ "ការផ្ទៀងផ្ទាត់អាសយដ្ឋានរបស់ចុងចោទ" [add hyperlink] ដាច់ដោយឡែកមួយ ជាមួយបណ្តឹងរបស់អ្នកផងដែរ ដោយបញ្ជាក់ថា អ្នកបានផ្ទៀងផ្ទាត់អាសយដ្ឋានផ្ញើសំបុត្ររបស់ចុងចោទ ក្នុងលក្ខណៈដែលបានថ្លែងក្នុងទម្រង់បែបបទនោះ។ ប្រសិនបើអ្នកមិនធ្វើដូច្នោះទេ ហើយចុងចោទមិនមកបង្ហាញខ្លួន ជាធម្មតា អ្នកប្រហែលជាមិនអាចទទួលការវិនិច្ឆ័យកំបាំងមុខ ដោយអនុគ្រោះចំពោះអ្នកឡើយ ហើយបណ្តឹងរបស់អ្នកនឹងត្រូវបានលើកចោល ទោះបីជាអ្នកអាចដាក់វាឡើងវិញក៏ដោយ។
"ជំនួញ" និង "ពាណិជ្ជកម្ម" មានអត្ថន័យដូចគ្នានៅក្នុងច្បាប់ការពារអ្នកប្រើប្រាស់, ច្បាប់ទូទៅរបស់រដ្ឋម៉ាសាជូសេត c. 93A, § 1 [add hyperlink]។ ពួកវារួមបញ្ចូលទាំង ទំនាក់ទំនងពាណិជ្ជកម្មភាគច្រើនរវាងអ្នកលក់ ឬ អ្នកផ្តល់សេវា និងអ្នកប្រើប្រាស់ ក្នុងបរិបទអាជីវកម្ម ប៉ុន្តែមិនមែនជាប្រតិបត្តិការពាណិជ្ជកម្មឯកជនដាច់ដោយឡែកឡើយ។ ពួកវាមិនរួមបញ្ចូលការជួលទីលំនៅដែលមានបីបន្ទប់ ឬក៏តិចជាងនេះ ដែលអ្នកជាម្ចាស់ និង ដែលនោះក៏ជាទីលំនៅចម្បងរបស់អ្នកដែរឡើយ លុះត្រាតែអ្នកជាម្ចាស់ផង, ជាអ្នកគ្រប់គ្រងផង ឬក៏ជាប់ពាក់ព័ន្ធនឹងការជួលទីលំនៅផ្សេងទៀត។

## 11. តើចុងចោទទទួលដំណឹងពីបណ្តឹងនេះដូចម្តេច?

ចុងចោទត្រូវបានផ្ញើឲ្យនូវឯកសារចម្លងមួយច្បាប់នៃ "សេចក្តីថ្លែងការណ៍អំពីបណ្តឹង និង សេចក្តីជូនដំណឹងអំពីការកាត់ក្តី" តាមរយៈសំបុត្រថ្នាក់ទីមួយ។ ប្រសិនបើចុងចោទរស់នៅក្រៅរដ្ឋ គេនឹងទទួលដំណឹងតាមសំបុត្រដែលមានការបញ្ជាក់។ ប្រភេទនៃសេចក្តីជូនដំណឹងទាំងពីរនឹងផ្តល់ជូនដោយតុលាការ បន្ទាប់ពីបានដាក់ទម្រង់បែបបទ "សេចក្តីថ្លែងការណ៍អំពីបណ្តឹង និង សេចក្តីជូនដំណឹងអំពីការកាត់ក្តី"។



This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.

## 12. តើរឿងក្ដីរបស់ខ្ញុំនឹងបន្តទៅមុខទៀតដែរឬទេ ប្រសិនបើចុងចោទមិនបានទទួលសេចក្ដីជូនដំណឹង?

ប្រសិនបើការិយាល័យប្រៃសណីយ៍មិនអាចជូនដំណឹង ("បម្រើជូន") ចុងចោទបាន ហើយសំបុត្រនោះត្រូវបានត្រឡប់ទៅតុលាការវិញ រឿងក្ដីរបស់អ្នកមិនអាចបន្តទៅមុខទៀតបានឡើយ។ ប្រសិនបើសំបុត្រនោះមិនត្រឡប់មកវិញ ប៉ុន្តែក្រោយមកបានបង្ហាញថាមិនបានប្រគល់ឲ្យ ឬក៏បានផ្ញើទៅអាសយដ្ឋានខុស ការវិនិច្ឆ័យទាំងឡាយដែលអ្នកបានទទួលអាចត្រូវបានចាត់ជាមោឃៈ។ ដោយសារមូលហេតុនេះ វាចាំបាច់ដែលថា អ្នកត្រូវប្រាកដថាអាសយដ្ឋានផ្ញើសំបុត្ររបស់ចុងចោទដែលបានបញ្ចូលលើទម្រង់បែបបទ "សេចក្ដីថ្លែងការណ៍អំពីបណ្ដឹង និង សេចក្ដីជូនដំណឹងអំពីការកាត់ក្ដី" គឺត្រឹមត្រូវ។

## 13. តើត្រូវការមេធាវីដែរឬទេ នៅក្នុងតុលាការបណ្ដឹងតូចតាច?

ទេ ប៉ុន្តែអន កអាចជួលប្រែ ប្រសិនបើអន កចង់។
ល្វេកអនកអាចរកជំនួយប្រឹ្ឋល្ នឯងៗ នៅបណាហា ល័យស្ទនរ ្ត បន់ល្វេកអនកឬណាហា ល័យច្ចប់ ី
ផែនក្ត្បល្ខ្ក្ភរក ៃ, the Trial Court Law Libraries or MassLegal Help
(www.MassLegalHelp.org),

## 14. តើចុងចោទត្រូវបានតម្រូវឲ្យដាក់ឯកសារចម្លើយដែរឬទេ?

ចុងចោទអាចដាក់ទម្រង់បែបបទចម្លើយ [add hyperlink] ឬក៏គេអាចផ្ញើលិខិតដែលបានចុះហត្ថលេខាជូនតុលាការ ដែលថ្លែងយ៉ាងច្បាស់ និង សាមញ្ញពីមូលហេតុដែលដើមចោទមិនអាចឈ្នះក្ដី។ "ចម្លើយ" គួរថ្លែងបញ្ជាក់ផ្នែកជាក់លាក់នៃបណ្ដឹងដែលបានបដិសេធ។ ទោះជាយ៉ាងនេះក្ដី ចុងចោទមិនត្រូវបានតម្រូវឲ្យដាក់ឯកសារចម្លើយឡើយ។ ចុងចោទត្រូវតែផ្ញើជូនដើមចោទនូវឯកសារចម្លងនៃចម្លើយ ប្រសិនបើបានដាក់មួយ។
នៅក្នុងទម្រង់បែបបទចម្លើយ ឬ ក្នុងទម្រង់បែបបទបណ្ដឹងតប [add hyperlink] ដាច់ដោយឡែក ឬក៏លិខិតទៅតុលាការ ចុងចោទអាចថ្លែងជាលាយលក្ខណ៍អក្សរនូវបណ្ដឹងប្រឆាំងនឹងដើមចោទនៅក្នុងយុត្តាធិការរបស់តុលាការបណ្ដឹងតូចតាច។ (នេះគេហៅថាបណ្ដឹងតប។) បណ្ដឹងទាំងពីរនឹងត្រូវបានចាត់ទុកថាជារឿងក្ដីតែមួយ ប្រសិនបើចុងចោទផ្ញើឯកសារចម្លងនៃបណ្ដឹងរបស់គេជូនដើមចោទ យ៉ាងហោចណាស់ដប់ថ្ងៃ មុនថ្ងៃកាត់ក្ដីដែលបានគ្រោង ឬក៏ប្រសិនបើតុលាការបញ្ជាថាពួកវាត្រូវបានចាត់ទុកដូច្នោះ។ បណ្ដឹងតបនោះគឺមិនមែនខានមិនបានឡើយ។ ដើមចោទមិនចាំបាច់ដាក់ចម្លើយជាលាយលក្ខណ៍អក្សរចំពោះបណ្ដឹងតបរបស់ចុងចោទឡើយ។

## 15. ចុះប្រសិនបើចុងចោទព្រមទទួលថាជំពាក់ប្រាក់ទាំងអស់?

គេគួរទាក់ទងដើមចោទ និង រៀបចំធ្វើការសងប្រាក់។ ចុងចោទមិនត្រូវបានតម្រូវឲ្យធ្វើការសងប្រាក់ណាមួយពីចំណូលលើកលែង (មើលខាងក្រោម) ឡើយ។ ប្រសិនបើការសងប្រាក់គ្រប់ចំនួនមិនបានធ្វើឡើង មុនថ្ងៃកាត់ក្ដីទេ ទាំងដើមចោទ និង ចុងចោទត្រូវតែបង្ហាញខ្លួនក្នុងតុលាការនៅថ្ងៃកាត់ក្ដី លុះត្រាតែពួកគេប្រគល់ជូនតុលាការមុនថ្ងៃកាត់ក្ដីនូវទម្រង់បែបបទ "កិច្ចព្រមព្រៀងសម្រាប់ការវិនិច្ឆ័យ និង សម្រាប់ការបញ្ជាឲ្យសងប្រាក់" [add hyperlink] ដែលបានចុះហត្ថលេខាដោយភាគីទាំងពីរ។ តុលាការនឹងព្រមទទួលកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ តែក្នុងករណីដែលវាត្រូវបានប្រគល់តាមទម្រង់បែបបទ "កិច្ចព្រមព្រៀងសម្រាប់ការវិនិច្ឆ័យ និង សម្រាប់ការបញ្ជាឲ្យសងប្រាក់" ផ្លូវការប៉ុណ្ណោះ។ ប្រសិនបើដើមចោទ និង ចុងចោទបានព្រមព្រៀងគ្នានៅថ្ងៃកាត់ក្ដី នោះពួកគេគួរប្រគល់ជូនតុលាការនូវទម្រង់បែបបទ "កិច្ចព្រមព្រៀងសម្រាប់ការវិនិច្ឆ័យ និង សម្រាប់ការបញ្ជាឲ្យសងប្រាក់" ដែលចុះហត្ថលេខាដោយភាគីទាំងពីរ។

## 16. ចុះប្រសិនបើចុងចោទព្រមទទួលថាជំពាក់ប្រាក់ ប៉ុន្តែត្រូវការពេលដើម្បីសង?

គេគួរទាក់ទងដើមចោទ និង ព្យាយាមធ្វើកិច្ចព្រមព្រៀងរៀបគម្រោងសំណង។ ចុងចោទមិនត្រូវបានតម្រូវឲ្យធ្វើការសងប្រាក់ពីចំណូលដែលបានលើកលែង (មើលខាងក្រោម) ឡើយ។ ទាំងដើមចោទ និង ចុងចោទត្រូវតែបង្ហាញខ្លួនក្នុងតុលាការនៅថ្ងៃកាត់ក្ដី លុះត្រាតែពួកគេប្រគល់ជូនតុលាការមុនថ្ងៃកាត់ក្ដីនូវទម្រង់បែបបទ "កិច្ចព្រមព្រៀងសម្រាប់ការវិនិច្ឆ័យ និង សម្រាប់ការបញ្ជាឲ្យសងប្រាក់" [add hyperlink] ដែលបានចុះហត្ថលេខាដោយភាគីទាំងពីរ។ តុលាការនឹងព្រមទទួលកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ តែក្នុងករណីដែលវាត្រូវបានប្រគល់តាមទម្រង់បែបបទ "កិច្ចព្រមព្រៀងសម្រាប់ការវិនិច្ឆ័យ និង សម្រាប់ការបញ្ជាឲ្យសងប្រាក់" ផ្លូវការប៉ុណ្ណោះ។ ប្រសិនបើដើមចោទ និង ចុងចោទបានព្រមព្រៀងគ្នានៅថ្ងៃកាត់ក្ដី នោះពួកគេគួរប្រគល់ជូនតុលាការនូវទម្រង់បែបបទ "កិច្ចព្រមព្រៀងសម្រាប់ការវិនិច្ឆ័យ និង សម្រាប់ការបញ្ជាឲ្យសងប្រាក់" ដែលចុះហត្ថលេខាដោយភាគីទាំងពីរ។ ប្រសិនបើភាគីទាំងពីរមិនអាចឈានដល់ការព្រមព្រៀងគ្នាសម្រាប់គម្រោងសំណងទេ ចុងចោទត្រូវតែបំពេញរបាយការណ៍ហិរញ្ញវត្ថុ [add hyperlink] និង ពន្យល់ជូនតុលាការនូវមូលហេតុរបស់គេក្នុងការស្នើសុំពន្យារពេលដើម្បីសង។

## 17. ចុះប្រសិនបើចុងចោទយល់ថាគាត់មិនជំពាក់អ្វីទាំងអស់ ឬ ជំពាក់តែប្រាក់ខ្លះដែលបានប្ដឹងនោះ?

គេត្រូវតែបង្ហាញខ្លួនក្នុងតុលាការនៅថ្ងៃកាត់ក្ដី។ គេនឹងអាចជំទាស់ថាតើដើមចោទសំអាងដូចម្ដេចបានជាទាមទារចំនួនដែលបានប្ដឹង។

## 18. ចុះប្រសិនបើចុងចោទយល់ថាដើមចោទជាអ្នកជំពាក់ប្រាក់គាត់វិញ?

ចុងចោទគួរបញ្ជាក់ពីចម្លើយរបស់គេ ឬក៏ប្រាប់តុលាការ រួចហើយធ្វើសំណេរជាលាយលក្ខណ៍អក្សរថា ដើមចោទជំពាក់ប្រាក់គាត់។ បណ្ដឹងដើមរបស់ដើមចោទ និង បណ្ដឹងរបស់ចុងចោទប្រឆាំងនឹងដើមចោទ (ដែលគេហៅថា "បណ្ដឹងតប") អាចត្រូវបានចាត់ទុកថាជារឿងក្ដីតែមួយ និង កាត់ក្ដីនៅកាលបរិច្ឆេទដែលបណ្ដឹងដើមត្រូវបានគ្រោង។ ប្រសិនបើចុងចោទដាក់ឯកសារបណ្ដឹងតបជាលាយលក្ខណ៍អក្សរ ចុងចោទត្រូវតែផ្ញើឯកសារចម្លងមួយច្បាប់ជូនដើមចោទ។
ចុងចោទអាចថ្លែងជាលាយលក្ខណ៍អក្សរនូវបណ្ដឹងតបទាំងឡាយប្រឆាំងនឹងដើមចោទនៅក្នុងយុត្តាធិការនៃតុលាការបណ្ដឹងតូចតាច។ បណ្ដឹងតបអាចត្រូវបានរួមបញ្ចូលក្នុងចម្លើយជាលាយលក្ខណ៍អក្សរ ប្រសិនបើចុងចោទដាក់មួយ ឬ ក្នុងបណ្ដឹងតបដាច់ដោយឡែក ឬក៏លិខិតផ្ញើទៅតុលាការ។ តុលាការក៏អាចអនុញ្ញាតឲ្យធ្វើបណ្ដឹងតបដោយផ្ទាល់មាត់ និង ធ្វើសំណេរជាលាយលក្ខណ៍អក្សរ នៅពេលក្រោយផងដែរ។ បណ្ដឹងទាំងពីរនឹងត្រូវបានចាត់ទុកថាជារឿងក្ដីតែមួយ ប្រសិនបើចុងចោទផ្ញើតាមប្រៃសណីយ៍នូវឯកសារចម្លងនៃបណ្ដឹងរបស់គេជូនដើមចោទ យ៉ាងហោចណាស់ដប់ថ្ងៃ មុនថ្ងៃកាត់ក្ដីដែលបានគ្រោង ឬក៏ប្រសិន



This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.

បើតុលាការីបញ្ជាឲ្យចាត់ទុកពួកវាដូច្នោះ។ បណ្តឹងតបនោះគឺមិនមែនខានមិនបានឡើយ។ ដើមចោទមិនចាំបាច់ដាក់ចម្លើយជាលាយលក្ខណ៍អក្សរចំពោះបណ្តឹងតបរបស់ចុងចោទឡើយ។

## 19. តើពេលណា ឬ កន្លែងណាដែលដើមចោទ និង ចុងចោទត្រូវទៅតុលាការ?

លុះត្រាតែដើមចោទ និង ចុងចោទផ្សះផ្សារឿងក្តីនេះមុនថ្ងៃកាត់ក្តី បើមិនដូច្នោះទេ ភាគីទាំងពីរត្រូវតែបង្ហាញខ្លួនក្នុងតុលាការនៅកាលបរិច្ឆេទដែលរឿងក្តីនេះត្រូវបានគ្រោងសម្រាប់ការកាត់ក្តី។

## 20. តើមានការសម្រុះសម្រួលដែរឬទេចំពោះបណ្តឹងតូចតាច?

ការសម្រុះសម្រួលមាននៅតុលាការជាច្រើន នៅថ្ងៃកាត់ក្តី។ នៅពេលលើករឿងក្តីនោះមក ប្រសិនបើមានការសម្រុះសម្រួល អ្នកនឹងត្រូវបានសួរថាតើអ្នកចង់សម្រុះសម្រួលបណ្តឹងរបស់អ្នកដែរឬទេ។

## 21. ចុះប្រសិនបើខ្ញុំមិនអាចមកតុលាការនៅថ្ងៃកាត់ក្តី?

អ្នកគួរហៅទូរស័ព្ទ ឬ សរសេរទៅបុគ្គលនៅភាគីម្ខាងទៀត និង សុំគេឲ្យយល់ព្រមពន្យារពេល (“លើកពេល”) រឿងក្តី។ ការលើកពេលគួរតែធ្វើឡើងដោយមានមូលហេតុល្អប៉ុណ្ណោះ ដូចជាមានជំងឺ, ការសង្គ្រោះបន្ទាន់ ឬក៏សាក្សីមិនទំនេរ។ ប្រសិនបើភាគីទាំងពីរយល់ព្រម ឬក៏ប្រសិនបើភាគីម្ខាងទៀតមិនយល់ព្រម ឬ ប្រសិនបើអ្នកមិនអាចទាក់ទងបុគ្គលនៅភាគីម្ខាងទៀត អ្នកត្រូវតែសរសេរលិខិតជូនស្មៀនតុលាការីនៃតុលាការដោយសុំឲ្យតុលាការផ្តល់ជូនអ្នកនូវការលើកពេល។ ចូរកុំរង់ចាំរហូតដល់នាទីចុងក្រោយ។ ប្រសិនបើភាគីម្ខាងទៀតធ្វើសំណើសមហេតុផលសម្រាប់ការលើកពេល វាអាចបង្ការជូនអ្នកនូវទំនាស់ខ្លះ ប្រសិនបើអ្នកយល់ព្រមចំពោះសំណើ។

## 22. ចុះប្រសិនបើខ្ញុំមិនមកតុលាការនៅថ្ងៃកាត់ក្តី?

ប្រសិនបើដើមចោទមិនមកបង្ហាញខ្លួនសម្រាប់ការកាត់ក្តី ហើយចុងចោទមកបង្ហាញខ្លួន តុលាការនឹងធ្វើការវិនិច្ឆ័យឲ្យចុងចោទ។ ប្រសិនបើទាំងដើមចោទ និង ចុងចោទមិនមកបង្ហាញខ្លួនសម្រាប់ការកាត់ក្តី បណ្តឹងនោះនឹងត្រូវលើកចោល។ ប្រសិនបើចុងចោទមិនមកបង្ហាញខ្លួនសម្រាប់ការកាត់ក្តី ហើយដើមចោទមកបង្ហាញខ្លួន តុលាការទំនងជាធ្វើការវិនិច្ឆ័យកំបាំងមុខ និង បញ្ជាឲ្យចុងចោទសងចំនួនដែលបានប្តឹងទាមទារ។ តុលាការីអាចសុំឲ្យដើមចោទបង្ហាញព័ស្តុតាងខ្លះនៃបណ្តឹងសូម្បីតែចុងចោទមិនមានវត្តមានក៏ដោយ។

## 23. តើខ្ញុំត្រូវត្រៀមខ្លួនសម្រាប់ការកាត់ក្តីដូចម្តេច?

វាអាចមានប្រយោជន៍ក្នុងការសរសេរជាមុននូវអង្គហេតុនៃរឿងក្តីនេះតាមលំដាប់លំដោយដែលបានកើតឡើង។ នេះនឹងជួយអ្នករៀបចំគំនិតរបស់អ្នក និង ធ្វើបទបង្ហាញច្បាស់លាស់អំពីសាច់រឿងរបស់អ្នក។ នៅថ្ងៃកាត់ក្តី អ្នកត្រូវតែនាំមកជាមួយអ្នកនូវសាក្សីទាំងឡាយ, មូលប្បទានបត្រ, វិក្កយបត្រ, ឯកសារ, រូបថត ឬ លិខិតដែលនឹងជួយអ្នកបង្ហាញព័ស្តុតាងនៃរឿងក្តីរបស់អ្នក។ ប្រសិនបើអ្នកកំពុងប្រគល់ឯកសារ ដូចដែលបានបង្ហាញ នៅក្នុងការកាត់ក្តី សូមនាំមកជាមួយនូវឯកសារចម្លងប៉ុន្មានច្បាប់សម្រាប់តុលាការី និង សម្រាប់ចុងចោទផង។ ប្រសិនបើអ្នកត្រូវការឲ្យសាក្សីមកតុលាការ ប៉ុន្តែសាក្សីមិនមក សូមសុំឲ្យស្មៀននៅការិយាល័យរបស់តុលាការីចេញដីកាកោះហៅសាក្សី ដែលបន្ទាប់មក អ្នកត្រូវតែរៀបចំឲ្យតម្រួត ឬ អនុប្រធានមន្ត្រីអនុវត្តច្បាប់ប្រគល់ជូនសាក្សី។ អ្នកប្រហែលជាត្រូវការសាក្សីជំនាញដើម្បីបញ្ជាក់ពីបញ្ហាខ្លះដែលមិនមែនស្ថិតនៅក្នុងបទពិសោធន៍ទូទៅ។ ច្បាប់ដែលគ្របដណ្តប់លើបណ្តឹងតូចតាចគឺដូចគ្នានឹងច្បាប់សម្រាប់បណ្តឹងធំៗ លើកលែងតែថា វាបានប្រើនីតិវិធីងាយស្រួលប៉ុណ្ណោះ។ ដើមចោទត្រូវតែបញ្ជាក់ថាបណ្តឹងនោះគឺជាបណ្តឹងមួយដែលច្បាប់ទទួលស្គាល់ និង ថាចុងចោទជាអ្នកទទួលខុសត្រូវ បើមិនដូច្នោះទេ តុលាការីនឹងធ្វើសេចក្តីសម្រេចសម្រាប់ចុងចោទ។

FAQ Small Claims_KhmerKhmer 08/2012www.mass.gov/courts/forms

## 24. តើនឹងមានអ្វីកើតឡើងនៅថ្ងៃកាត់ក្តី?

ត្រូវប្រាកដថាមកឲ្យទាន់ពេល។ ប្រសិនបើរឿងក្តីរបស់អ្នកមិនបានដោះស្រាយដោយអ្នកសម្រុះសម្រួលទេ ការកាត់ក្តីនឹងធ្វើឡើងនៅចំពោះមុខតុលាការី។ ដើមចោទនឹងត្រូវបានសុំឲ្យប្រាប់ភាគីរបស់គេនូវសាច់រឿងនោះ រួចហើយចុងចោទនឹងប្រាប់ភាគីរបស់គេ។ ភាគីនីមួយៗនឹងមានឱកាសសួរសំណួរដល់ភាគីម្ខាងទៀត និង សាក្សីរបស់ភាគីម្ខាងទៀត។ ដើម្បីឈ្នះក្តី ច្បាប់តម្រូវឲ្យដើមចោទបញ្ជាក់អំពីសុពលភាពនៃបណ្តឹងរបស់គេ។

## 25. ចុះប្រសិនបើភាគីណាមួយចង់លើកពេល?

ប្រសិនបើភាគីទាំងពីរមានវត្តមាននៅពេលលើករឿងក្តីនោះមកកាត់ រឿងក្តីនោះនឹងបន្តទៅមុខ លុះត្រាតែមានមូលហេតុល្អមួយសម្រាប់ការលើកពេល។ ប្រសិនបើអ្នកបានត្រៀមខ្លួនជាស្រេចដើម្បីបន្តទៅមុខ ហើយភាគីម្ខាងទៀតចង់លើកពេល ត្រូវប្រាកដថាអ្នកជូនដំណឹងដល់តុលាការី ប្រសិនបើអ្នកជំទាស់។

## 26. តើតុលាការីនឹងធ្វើអ្វីខ្លះ?

តុលាការីនឹងធ្វើសេចក្តីសម្រេច។ សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេច (ដែលគេហៅថា “ការវិនិច្ឆ័យ”) នឹងផ្តល់ជូន ឬ ផ្ញើជូនភាគីនីមួយៗ។

## 27. ខ្ញុំបានចាញ់ក្តីរបស់ខ្ញុំនៅចំពោះមុខតុលាការី។ តើខ្ញុំត្រូវធ្វើអ្វី?

ប្រសិនបើអ្នកបានប្តឹងភាគីម្ខាងទៀត និង បានចាញ់ក្តី ហើយតុលាការីមិនកាត់ក្តីឲ្យអ្នកទទួលប្រាក់ សេចក្តីសម្រេចនោះគឺចុងក្រោយ។ អ្នកមិនអាចប្តឹងសាទុក្ខពីសេចក្តីសម្រេចរបស់តុលាការីប្រឆាំងនឹងអ្នកឡើយ។
ប្រសិនបើអ្នកត្រូវបានប្តឹងដោយភាគីម្ខាងទៀត និង បានចាញ់ក្តី ហើយតុលាការីបានបញ្ជាឲ្យអ្នកសងប្រាក់ជូនភាគីម្ខាងទៀត អ្នកត្រូវធ្វើកិច្ចការមួយក្នុងចំណោមកិច្ចការបួនខាងក្រោម៖

### A. សងការវិនិច្ឆ័យគ្រប់ចំនួន ក្នុងរយៈពេលដែលបានបញ្ជា

អ្នកត្រូវតែសងការវិនិច្ឆ័យគ្រប់ចំនួន ប្រសិនបើអ្នកមានលទ្ធភាពខាងហិរញ្ញវត្ថុក្នុងការធ្វើដូច្នោះ។ អ្នកមិនត្រូវបានតម្រូវឲ្យសង


This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.

ការវិនិច្ឆ័យពីចំណូលដែលបានលើកលែងដោយច្បាប់ឡើយ។ ប្រសិនបើអ្នកមិនសងចំនួនដែលបានបញ្ជាទេ ហើយអ្នកមាន
លទ្ធភាពធ្វើដូច្នោះ អ្នកអាចត្រូវបានចាត់ទុកថាមិនគោរពតុលាការ និង អាចជាប់ពន្ធនាគារ ឬក៏ត្រូវបង់សោហ៊ុយបន្ថែម។
សងប្រាក់គ្រប់ចំនួនដោយផ្ទាល់ជូនភាគីម្ខាងទៀត (“ម្ចាស់បំណុលនៃការវិនិច្ឆ័យ”) លុះត្រាតែតុលាការបានបញ្ជាផ្សេងពីនេះ។
ម្ចាស់បំណុលនៃការវិនិច្ឆ័យត្រូវតែជូនដំណឹងដល់តុលាការជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 10 ថ្ងៃ បន្ទាប់ពីការវិនិច្ឆ័យត្រូវបាន
សងគ្រប់ចំនួន។ អ្នកត្រូវប្រាកដថាធ្វើដូច្នេះ ដើម្បីការពារកំណត់ត្រាកិត្តិយសរបស់អ្នក។ ប្រសិនបើម្ចាស់បំណុលនៃការវិនិច្ឆ័យ
បដិសេធក្នុងការធ្វើដូច្នេះ អ្នកអាចសុំឲ្យតុលាការធ្វើការកំណត់ដូចនោះលើកំណត់ត្រាឯកសាររឿងក្តី។ ប្រសិនបើតុលាការបាន
បញ្ជាអ្នកឲ្យប្រគល់ទ្រព្យជូនម្ចាស់បំណុលនៃការវិនិច្ឆ័យវិញ អ្នកត្រូវតែធ្វើដូច្នោះ។

## B. សុំឲ្យតុលាការីកំណត់គម្រោងសំណង

ប្រសិនបើតុលាការីបានរៀបគម្រោងសវនាការសំណង នៅក្នុងសវនាការសំណងនោះ អ្នកអាចស្នើឲ្យតុលាការីចេញបញ្ជាអំពី
គម្រោងសំណងដែលអ្នកអាចលៃលកធ្វើបាន ឬ កំណត់ថាអ្នកមិនអាចសងអ្វីទាំងអស់ក្នុងពេលនេះ។ ប្រសិនបើអ្នកស្នើសុំ
គម្រោងសំណង ឬ ការពន្យារពេលសងប្រាក់ សូមទទួលទម្រង់បែបបទ “របាយការណ៍ហិរញ្ញវត្ថុរបស់កូនបំណុលនៃការវិនិច្ឆ័យ”
នៅទីនេះ ឬ ពីការិយាល័យរបស់ស្មៀន, បំពេញវា និង នាំវាមកជាមួយអ្នកទៅក្នុងសវនាការ អមនឹងឯកសារទាំងឡាយដែលអ្នក
មាន ទាក់ទិននឹងស្ថានភាពហិរញ្ញវត្ថុរបស់អ្នក (ឯកសារទទួលប្រាក់ពន្ធវិញ, សន្លឹកបៀវត្សរ៍។ល។)។
ចំណូលមួយចំនួនត្រូវបានលើកលែងពីការបញ្ជាឲ្យសងប្រាក់ដោយតុលាការ។ ដើម្បីមើលបញ្ជីនៃចំណូលដែលបានលើកលែងនោះ
សូមចុចទីនេះ [add hyperlink]។ ប្រសិនបើចំណូលរបស់អ្នកបានមកពីប្រភពទាំងនេះណាមួយ អ្នកគួរនាំមកជាមួយនូវព័ត៌មានខ្លះអំពីវា ទៅកាន់សវនាការត្រួតពិនិត្យការសងប្រាក់។ វាអាចកើតឡើងដែលថាបុគ្គលដែលមានចំណូលលើកលែងក៏អាចទទួល
បៀវត្សរ៍ពីការងារដែលអាចស្ថិតនៅក្រោមការបញ្ជាឲ្យសងប្រាក់ដែរ។ សូម្បីតែបុគ្គលម្នាក់ក្នុងពេលបច្ចុប្បន្នមិនមានលទ្ធភាព
ក្នុងការសងប្រាក់ ការវិនិច្ឆ័យអាចត្រូវបានអនុវត្តក្នុងពេល 20 ឆ្នាំ ប្រសិនបើស្ថានភាពហិរញ្ញវត្ថុរបស់បុគ្គលនោះប្រសើរឡើងក្នុង
អំឡុងពេលនោះ។
ប្រសិនបើតុលាការីមិនបានរៀបគម្រោងសវនាការសំណងទេ ហើយអ្នកចង់ស្នើសុំគម្រោងសំណង ឬ ការពន្យារពេលសងប្រាក់
ឬក៏ចំណូលរបស់អ្នកទាំងអស់បានមកពីប្រភពដែលបានលើកលែង សូមសុំឲ្យការិយាល័យស្មៀនរៀបគម្រោងសំណើរបស់អ្នកសុំ
សវនាការនៅចំពោះមុខតុលាការី - ចូរកុំរង់ចាំរហូតទាល់តែអ្នកត្រូវបានតម្រូវឲ្យមកតុលាការ បើមិនដូច្នោះទេ អ្នកនឹងទទួល
ខុសត្រូវចំពោះសោហ៊ុយបន្ថែម។
ម្ចាស់បំណុលនៃការវិនិច្ឆ័យអាចមិនទទួលដីកាអនុវត្តសាលក្រមក្នុងការរឹបអូស និង លក់ទ្រព្យសម្បត្តិរបស់អ្នកឡើយ រហូតទាល់
តែបន្ទាប់ពីសវនាការសំណងដំបូង (ឬ ប្រសិនបើមិនបានរៀបគម្រោងសវនាការសំណងទេ គឺរហូតដល់ 30 ថ្ងៃបន្ទាប់ពី
ការវិនិច្ឆ័យ)។ បន្ទាប់ពីនោះ ម្ចាស់បំណុលនៃការវិនិច្ឆ័យអាចធ្វើដូច្នោះ សូម្បីតែអ្នកនឹងធ្វើការសងប្រាក់តាមពេលក៏ដោយ
លុះត្រាតែអ្នកទាំងពីរយល់ព្រមថា គេនឹងមិនធ្វើដូច្នោះឡើយ ខណៈពេលអ្នកកំពុងធ្វើការសងប្រាក់។ ទ្រព្យរបស់បុគ្គលជាច្រើន
អាចត្រូវបានរឹបអូស និង លក់ដើម្បីជម្រះបំណុលនៃការវិនិច្ឆ័យ សូម្បីតែបុគ្គលនោះមានចំណូលដែលបានលើកលែងក៏ដោយ។

## C. ប្តឹងសាទុក្ខទៅចៅក្រម ឬ គណៈវិនិច្ឆ័យ

ប្រសិនបើអ្នកបានបង្ហាញខ្លួននៅក្នុងការកាត់ក្តីនៅចំពោះមុខតុលាការី ហើយអ្នកមិនយល់ព្រមជាមួយនឹងសេចក្តីសម្រេច
របស់តុលាការីអំពីបណ្តឹងរបស់ភាគីម្ខាងទៀត អ្នកអាចប្តឹងសាទុក្ខសុំការកាត់ក្តីមួយទៀតដោយចៅក្រមម្នាក់ ឬ គណៈវិនិច្ឆ័យ
មួយក្រុម។ ដើម្បីធ្វើដូច្នេះ ក្នុងរយៈពេល 10 ថ្ងៃ បន្ទាប់ពីអ្នកទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេច
របស់តុលាការី អ្នកត្រូវតែដាក់ទម្រង់បែបបទ “បណ្តឹងសាទុក្ខរបស់ចុងចោទ” របស់អ្នក (add hyperlink; សូមដាក់ឯកសារចម្លង
ប្តូនច្បាប់នៅតុលាការ) នៅការិយាល័យរបស់ស្មៀន ដោយបញ្ជាក់ថាតើអ្នកចង់បានការកាត់ក្តីដោយចៅក្រមម្នាក់ ឬ
គណៈវិនិច្ឆ័យមួយក្រុម ជាមួយនឹងថ្លៃប្តឹងសាទុក្ខ $25 (ប្រាក់មិនអាចដកវិញបាន) និង ប្រាក់ធានាប្តឹងសាទុក្ខ ឬ ប្រាក់កក់
$100 (ដែលអាចដកវិញបាន ប្រសិនបើអ្នកឈ្នះក្តីក្នុងពេលប្តឹងសាទុក្ខ ឬក៏ទុកជាតណទានសម្រាប់អ្វីដែលអ្នកជំពាក់ ប្រសិនបើ
អ្នកចាញ់ក្តីក្នុងពេលប្តឹងសាទុក្ខ)។ ប្រាក់ធានា ឬ ប្រាក់កក់ប្តឹងសាទុក្ខគឺច្រើនជាងនេះ ប្រសិនបើអ្នកគឺជាម្ចាស់ផ្ទះដែលត្រូវបាន
គេប្តឹងសម្រាប់ការប្រគល់ប្រាក់កក់នៃការជួលទីលំនៅមកវិញ។ ថ្លៃប្តឹងសាទុក្ខ និង ប្រាក់ធានាអាចត្រូវបានកាត់បន្ថយ ឬ
លើកលែង ប្រសិនបើអ្នកពិតជាក្រខ្លាំង។ នៅពេលប្តឹងសាទុក្ខ ចៅក្រម ឬ គណៈវិនិច្ឆ័យនឹងធ្វើសេចក្តីសម្រេចថ្មី ប៉ុន្តែអាចយក
សេចក្តីសម្រេចរបស់តុលាការីដែលបានធ្វើពីមុនមកគិតពិចារណា។
ប្រសិនបើអ្នកមិនមកបង្ហាញខ្លួននៅក្នុងការកាត់ក្តីចំពោះមុខតុលាការីទេ (នេះគេហៅថាកំបាំងមុខ) អ្នកមិនអាចប្តឹងសាទុក្ខ
លើសេចក្តីសម្រេចរបស់តុលាការីអំពីបណ្តឹងរបស់ភាគីម្ខាងទៀតឡើយ។

## D. ដាក់ញត្តិសុំមោឃភាពការវិនិច្ឆ័យ

មិនថាអ្នកបានបង្ហាញខ្លួននៅក្នុងការកាត់ក្តីចំពោះមុខតុលាការីឬក៏អត់ទេ អ្នកអាចសុំឲ្យតុលាការីធ្វើមោឃៈភាព (លុបចោល)
ការវិនិច្ឆ័យ ប្រសិនបើអ្នកមានមូលហេតុល្អមួយ។ សំណើបែបនេះត្រូវតែធ្វើឡើងក្នុងរយៈពេលមួយឆ្នាំ លុះត្រាតែវាផ្អែកលើការមិន
បានទទួលសេចក្តីជូនដំណឹងអំពីបណ្តឹងតូចតាចនោះ។ ដើម្បីធ្វើសំណើដូច្នោះ សូមសុំឲ្យការិយាល័យរបស់ស្មៀនជួយអ្នកដាក់
ឯកសារ និង រៀបគម្រោង “ញត្តិសុំមោឃភាពការវិនិច្ឆ័យ”។ ទម្រង់បែបបទនៃញត្តិនេះអាចរកបាននៅទីនេះ [add hyperlink]
និង នៅការិយាល័យរបស់ស្មៀន។

## 28. ខ្ញុំបានឈ្នះក្តីរបស់ខ្ញុំនៅចំពោះមុខតុលាការី។ តើខ្ញុំត្រូវធ្វើអ្វី?

ប្រសិនបើអ្នកត្រូវបានប្តឹងដោយភាគីម្ខាងទៀត ហើយបានឈ្នះក្តី ភាគីម្ខាងទៀតមិនអាចប្តឹងសាទុក្ខលើសេចក្តីសម្រេចរបស់
តុលាការីអំពីបណ្តឹងប្រឆាំងនឹងអ្នកឡើយ។
ប្រសិនបើអ្នកបានប្តឹងភាគីម្ខាងទៀត និង បានឈ្នះក្តី ហើយតុលាការីបានកាត់ឲ្យអ្នកទទួលប្រាក់ អ្នកមិនអាចប្រមូលប្រាក់
នោះឡើយ លុះត្រាតែពេលសម្រាប់ប្តឹងសាទុក្ខត្រូវបានបញ្ចប់ ឬ រហូតទាល់តែបណ្តឹងសាទុក្ខត្រូវបានចេញសេចក្តីសម្រេច។ ប្រសិន
បើគ្មានបណ្តឹងសាទុក្ខទេ ឬ ប្រសិនបើអ្នកឈ្នះក្តីម្តងទៀតនៅពេលប្តឹងសាទុក្ខ ទាំងនេះគឺជាជំហានខ្លះដែលអ្នកអាចធ្វើដើម្បី
ប្រមូលប្រាក់របស់អ្នក៖

## A. សុំសំណង

សុំឲ្យភាគីម្ខាងទៀត (“កូនបំណុលនៃការវិនិច្ឆ័យ”) សងប្រាក់ ឬ ប្រគល់ទ្រព្យសម្បត្តិមកវិញ តាមការបញ្ជារបស់តុលាការី។



This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.

## B. សវនាការសំណង

ប្រសិនបើតុលាការីបានរៀបគម្រោងសវនាការសំណង ហើយកូនបំណុលនៃការវិនិច្ឆ័យមិនសងប្រាក់មុនសវនាការនោះទេ តុលាការីនឹងពិនិត្យមើលលទ្ធភាពរបស់កូនបំណុលនៃការវិនិច្ឆ័យក្នុងការសងប្រាក់ ហើយអាចបញ្ជាឲ្យសងប្រាក់ភ្លាមៗ ឬ ធ្វើគម្រោងសំណង។ នៅសវនាការនោះ បន្ទុកគឺធ្លាក់លើអ្នកក្នុងការបង្ហាញថាកូនបំណុលនៃការវិនិច្ឆ័យអាចសងប្រាក់ដោយមិនប្រើចំណូលដែលបានលើកលែងដោយច្បាប់។ អ្នកអាចពិនិត្យមើលទម្រង់បែបបទ "របាយការណ៍ហិរញ្ញវត្ថុរបស់កូនបំណុលនៃការវិនិច្ឆ័យ" របស់គេ និង បង្ហាញព័ត៌មានទាំងឡាយជូនតុលាការី ដែលពាក់ព័ន្ធនឹងលទ្ធភាពរបស់កូនបំណុលនៃការវិនិច្ឆ័យក្នុងការសង។ ប្រសិនបើតុលាការីកំណត់ថាកូនបំណុលនៃការវិនិច្ឆ័យមិនមានលទ្ធភាពខាងហិរញ្ញវត្ថុក្នុងការសងប្រាក់ឥឡូវទេ អ្នកអាចស្នើឲ្យតុលាការីរៀបគម្រោងត្រួតពិនិត្យបញ្ហានោះ នៅថ្ងៃក្រោយ។ ចំណូលមួយចំនួនត្រូវបានលើកលែងពីការបញ្ជាឲ្យសងប្រាក់របស់តុលាការ។ ដើម្បីមើលបញ្ជីនៃចំណូលដែលបានលើកលែង សូមចុចទីនេះ [add hyperlink]។ ការបញ្ជាឲ្យសងប្រាក់របស់តុលាការនឹងមិនរួមបញ្ចូលនូវចំណូលរបស់ចុងចោទដែលបានមកពីប្រភពទាំងនេះឡើយ។ វាអាចកើតឡើងដែលថាបុគ្គលម្នាក់ដែលមានចំណូលលើកលែងក៏អាចទទួលបៀវត្សពីការងារដែលអាចស្ថិតនៅក្រោមការបញ្ជាឲ្យសងប្រាក់ដែរ។
ទោះបីជាបុគ្គលម្នាក់ក្នុងពេលបច្ចុប្បន្នមិនអាចសងប្រាក់បាន ការវិនិច្ឆ័យអាចអនុវត្តក្នុងរយៈពេល 20 ឆ្នាំ ប្រសិនបើស្ថានភាពហិរញ្ញវត្ថុរបស់បុគ្គលនោះប្រសើរឡើងក្នុងអំឡុងពេលនេះ។

## C. សេចក្តីជូនដំណឹងឲ្យបង្ហាញមូលហេតុ

ប្រសិនបើតុលាការីមិនបានរៀបគម្រោងសវនាការសំណងទេ ហើយកូនបំណុលនៃការវិនិច្ឆ័យមិនសងប្រាក់នោះ សូមសុំឲ្យការិយាល័យស្មៀនចេញឲ្យអ្នកនូវ "សេចក្តីជូនដំណឹងឲ្យបង្ហាញមូលហេតុ" ដែលតម្រូវឲ្យកូនបំណុលនៃការវិនិច្ឆ័យបង្ហាញខ្លួននៅចំពោះមុខតុលាការ។ អ្នកត្រូវតែនៅតុលាការដែរនៅថ្ងៃនោះ។ អ្នកត្រូវតែបង់ថ្លៃជូនតម្រួតក្រុង ឬ អនុប្រធានមន្ត្រីអនុវត្តច្បាប់របស់ខោនធីឲ្យចាត់ការទម្រង់បែបបទនេះលើកូនបំណុលនៃការវិនិច្ឆ័យ ប៉ុន្តែចំនួននោះនឹងត្រូវបន្ថែមទៅលើចំនួនដែលកូនបំណុលនៃការវិនិច្ឆ័យជំពាក់។

## D. ដីកាចាប់ខ្លួន )ដីកាចាប់ខ្លួនខាងរដ្ឋប្បវេណី(

ប្រសិនបើកូនបំណុលនៃការវិនិច្ឆ័យមិនបង្ហាញខ្លួននៅសវនាការសំណង តាមការបញ្ជាទេ ឬ បន្ទាប់ពីបានឲ្យ "សេចក្តីជូនដំណឹងឲ្យបង្ហាញមូលហេតុ" សូមសុំឲ្យការិយាល័យស្មៀនរបស់តុលាការីចេញឲ្យអ្នកនូវ "ដីកាចាប់ខ្លួន" (ដីកាចាប់ខ្លួនខាងរដ្ឋប្បវេណី) កូនបំណុលនៃការវិនិច្ឆ័យ។ អ្នកត្រូវតែបង់ថ្លៃជូនតម្រួត ឬ អនុប្រធានមន្ត្រីអនុវត្តច្បាប់របស់ខោនធី ដើម្បីចាប់កូនបំណុលនៃការវិនិច្ឆ័យ និង នាំគេមកតុលាការ ប៉ុន្តែចំនួននោះនឹងបន្ថែមទៅលើអ្វីដែលកូនបំណុលនៃការវិនិច្ឆ័យជំពាក់។ សូមឲ្យលេខទូរស័ព្ទពេលថ្ងៃរបស់អ្នកទៅតម្រួត ឬ អនុប្រធានមន្ត្រីអនុវត្តច្បាប់របស់ខោនធី និង សុំឲ្យគេទាក់ទងអ្នក នៅពេលនាំខ្លួនកូនបំណុលនៃការវិនិច្ឆ័យទៅតុលាការ។

## E. ដីកាអនុវត្តសាលក្រម

ប្រសិនបើអ្នកអាចដឹងពីទ្រព្យសម្បត្តិមានតម្លៃណាមួយរបស់កូនបំណុលនៃការវិនិច្ឆ័យ (អចលនទ្រព្យ, យានយន្ត។ល។) ដែលអាចរឹបអូស និង លក់ដើម្បីសងចំពោះការវិនិច្ឆ័យរបស់អ្នក បន្ទាប់ពីសវនាការសំណង សូមសុំឲ្យការិយាល័យស្មៀនចេញឲ្យអ្នកនូវ "ដីកាអនុវត្តសាលក្រម"។ ប្រសិនបើមិនបានរៀបគម្រោងសវនាការសំណងទេ អ្នកអាចសុំដីកាអនុវត្តសាលក្រមក្នុងរយៈពេល 30 ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការវិនិច្ឆ័យ។ អ្នកត្រូវតែផ្តល់ដីកាអនុវត្តសាលក្រមជូនតម្រួត ឬ អនុប្រធានមន្ត្រីអនុវត្តច្បាប់របស់ខោនធីឲ្យរឹបអូស និង លក់ទ្រព្យសម្បត្តិរបស់កូនបំណុលនៃការវិនិច្ឆ័យ ដើម្បីសងចំពោះការវិនិច្ឆ័យ។ ទ្រព្យរបស់បុគ្គលនោះជាច្រើនអាចត្រូវបានរឹបអូស និង លក់ដើម្បីជម្រះបំណុលនៃការវិនិច្ឆ័យ សូម្បីតែបុគ្គលនោះមានចំណូលដែលបានលើកលែងក៏ដោយ។

**អ្នកត្រូវតែជូនដំណឹងតុលាការនៅពេលដែលអ្នកបានទទួលសំណងគ្រប់ចំនួន**

អ្នកត្រូវតែជូនដំណឹងការិយាល័យស្មៀនជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 10 ថ្ងៃ បន្ទាប់ពីអ្នកបានប្រមូលសំណងនៃការវិនិច្ឆ័យគ្រប់ចំនួន។ អ្នកអាចប្រើទម្រង់បែបបទ "ការជម្រះបំណុលនៃការវិនិច្ឆ័យ" របស់តុលាការ [add hyperlink] ឬ ទម្រង់បែបបទ "ការជម្រះបំណុលនៃការវិនិច្ឆ័យលើបណ្តឹងតប" [add hyperlink] ក្នុងគោលបំណងនោះ។ អ្នកមិនត្រូវបានតម្រូវឲ្យប្រើទម្រង់បែបបទជាក់លាក់ណាមួយឡើយ ប៉ុន្តែអ្នកគួររួមបញ្ចូលលេខកំណត់ត្រាឯកសាររឿងក្តីរបស់តុលាការនៅក្នុងការជូនដំណឹងរបស់អ្នក។

## 29. តើខ្ញុំត្រូវបង្ហាញខ្លួននៅក្នុងសវនាការសំណងដែលបានគ្រោងដែរឬទេ?

ប្រសិនបើដើមចោទដែលទទួលជោគជ័យ ("ម្ចាស់បំណុលនៃការវិនិច្ឆ័យ") ជូនដំណឹងការិយាល័យស្មៀនតុលាការីថាចុងចោទ ("កូនបំណុលនៃការវិនិច្ឆ័យ") អនុលោមតាមការបញ្ជាឲ្យសងប្រាក់របស់តុលាការី នោះគ្មានភាគីណាមួយត្រូវបានតម្រូវឲ្យបង្ហាញខ្លួននៅក្នុងសវនាការសំណងដែលបានគ្រោងឡើយ។
ប្រសិនបើកូនបំណុលនៃការវិនិច្ឆ័យមិនបានអនុលោមតាមការបញ្ជាឲ្យសងប្រាក់របស់តុលាការី នោះភាគីទាំងពីរត្រូវតែបង្ហាញខ្លួននៅសវនាការសំណងដែលបានគ្រោង។ ប្រសិនបើកូនបំណុលនៃការវិនិច្ឆ័យមិនមកបង្ហាញខ្លួនទេ ដោយគ្មានការជូនដំណឹងបន្ថែម តុលាការីអាចចេញដីកាចាប់ខ្លួនខាងរដ្ឋប្បវេណី (ដីកាចាប់ខ្លួន) សម្រាប់ការចាប់ខ្លួនគេ។

## 30. តើមានការលើកលែងចំណូលណាមួយពីការបញ្ជាឲ្យសងប្រាក់ដែរឬទេ?

ចំណូលរបស់ចុងចោទពីជំនួយសាធារណៈ និង កម្មវិធីផលប្រយោជន៍ខាងក្រោមត្រូវបានលើកលែងដោយច្បាប់ពីការបញ្ជាឲ្យសងប្រាក់នៃបណ្តឹងតូចតាចនៅតុលាការនានា៖
ផលប្រយោជន៍នៃភាពគ្មានការងារធ្វើ (G.L. c. 151A, § 36)
ផលប្រយោជន៍នៃសំណងកម្មករ (G.L. c. 152, § 47)
ផលប្រយោជន៍សន្តិសុខសង្គម (42 U.S.C. § 401)
ផលប្រយោជន៍ធានារ៉ាប់រងមនុស្សចាស់, អ្នកនៅរស់ & ជនពិការរបស់សហព័ន្ធ (42 U.S.C. § 407)
ចំណូលសន្តិសុខបន្ថែម (SSI) សម្រាប់មនុស្សចាស់, ជនពិការភ្នែក & ជនពិការ (42 U.S.C. § 1381[a])
ផលប្រយោជន៍ធានារ៉ាប់រងពិការភាពផ្សេងទៀត ដល់ទៅ $400 ក្នុងមួយសប្តាហ៍ (G.L. c. 175, § 110A)
ជំនួយសង្គ្រោះបន្ទាន់សម្រាប់មនុស្សចាស់ & ជនពិការ (ឥឡូវ G.L. c. 117A)



This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.

ផលប្រយោជន៍អតីតយុទ្ធជន (G.L. c. 115, § 5 ឬ 38 U.S.C. § 5301[a] ឬ 42 U.S.C. § 1001)
ផលប្រយោជន៍មេដាយនៃអតីតយុទ្ធជនដែលមានកិត្តយស (38 U.S.C. § 1562)
ផលប្រយោជន៍នៃជំនួយអន្តរកម្មចំពោះគ្រួសារដែលមានក្មេងក្នុងបន្ទុក (AFDC) (G.L. c. 118, §10)
ផលប្រយោជន៍នៃការផ្តល់ជូននូវសេវាសុខភាពដល់ម្តាយ និង ទារក (42 U.S.C. § 701)
ផលប្រយោជន៍ជំនួយសាធារណៈផ្សេងទៀត (G.L. c. 235, § 34, ទីដប់ប្រាំ)
បន្ថែមលើនេះ បំណែកមួយចំនួននៃបៀវត្ស ឬ ការបង់ប្រាក់ចូលនិវត្តន៍ដោយផ្អែកលើការងារ ត្រូវបានលើកលែងដោយច្បាប់ពីការបញ្ជាឲ្យសងប្រាក់នេះ។ ចំនួននៃការលើកលែងគឺ $400 ឬ 85% នៃចំណូលសុទ្ធប្រចាំសប្តាហ៍ គឺមួយណាដែលធំជាង។ “ចំណូលសុទ្ធប្រចាំសប្តាហ៍” គឺជាបៀវត្សដុល ឬ ការបង់ប្រាក់ចូលនិវត្តន៍តាមពេលដោយផ្អែកលើការងារ ដកនឹងការកាត់ផ្សេងៗដែលបានតម្រូវដោយច្បាប់ (រួមបញ្ចូលទាំងពន្ធកាត់ទុក, សន្តិសុខសង្គម [fica] និង ពន្ធចូលនិវត្តន៍របស់និយោជិតសាធារណៈដែលចាំបាច់)។ កូនបំណុលអាចមិនកាត់ការកាត់ដែលស្ម័គ្រចិត្តទាំងឡាយ, ពន្ធសហគមន៍ ឬ ដីកាកោះហៅកូនបំណុល។ ការលើកលែងរបស់សហព័ន្ធអប្បបរមាស្មើនឹងបៀវត្សអតិបរមារបស់សហព័ន្ធ ($7.25 នៅថ្ងៃ 7/24/09) គុណនឹង 30 ឬ $218 (15 U.S.C. §§ 1671-1677)។ ច្បាប់ម៉ាសាជូសេតលើកលែង $125 ដំបូងនៅក្នុង “បៀវត្សដែលជំពាក់ . . . សម្រាប់ពលកម្មដែលបានធ្វើ ឬ សេវាកម្មដែលបានផ្តល់ឲ្យ" (G.L. c. 224, § 16 & c. 246, § 28) ប៉ុន្តែ ជាធម្មតា គឺតិចជាការលើកលែងរបស់សហព័ន្ធ។

## 31. ប្រសិនបើខ្ញុំឈ្នះក្តីរបស់ខ្ញុំ តើខ្ញុំត្រូវជូនដំណឹងដល់តុលាការដែរឬទេ នៅពេលដែលខ្ញុំបានទទួលសំណង?

ត្រូវតែធ្វើ។ អ្នកត្រូវបានតម្រូវឲ្យជូនដំណឹងតុលាការជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 10 ថ្ងៃបន្ទាប់ពីអ្នកប្រមូលបានសំណងនៃការវិនិច្ឆ័យរបស់តុលាការគ្រប់ចំនួន។ អ្នកមិនត្រូវប្រើទម្រង់ជាក់លាក់ណាមួយឡើយ ប៉ុន្តែត្រូវរួមបញ្ចូលលេខកំណត់ត្រាឯកសាររឿងក្តីរបស់តុលាការ នៅក្នុងសេចក្តីជូនដំណឹងរបស់អ្នក។ អ្នកអាចប្រើទម្រង់បែបបទ ការទទួលស្គាល់អំពីការជម្រះបំណុលនៃការវិនិច្ឆ័យ [add hyperlink] ឬ ការទទួលស្គាល់អំពីការជម្រះបំណុលនៃការវិនិច្ឆ័យលើបណ្តឹងតប [add hyperlink] ដើម្បីជូនដំណឹងតុលាការ។


This document was developed under Grant No. 11-T-162 of the State Justice Institute. The form does not necessarily represent the official position or policies of the State Justice Institute.